**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះវិហារ**
-សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៥
ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦
-សំណុំរឿងជំនុំជម្រះលេខ ០៤
ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០
-សាលក្រមលេខ **១៤** "ឆ"
ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២១

# គាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះវិហារ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តព្រះវិហារ សាលសវនាការ កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង០៩ និង ៣០ នាទី ព្រឹក កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១។

**ដែលមានសមាសភាពដូចតទៅ:**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ។

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះវិហារ។

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តព្រះវិហារ ។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានជនជាប់ចោទ ៖

ឈ្មោះ [redacted] សារុម ហៅ ឈុន សារុំ ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើចំការ និងជាប្រធានសាខាសារព័ត៌មានតាព្រហ្មប្រចាំខេត្តពោធិ៍សាត់ ទីកន្លែងកំណើតស្ថិតនៅ [redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិថ្កុកដង្កោ ឃុំថ្កុកដង្កោ ស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] នឹម (ស) ម្តាយឈ្មោះ យ៉ន់ (ស) ប្រពន្ធឈ្មោះ [redacted] ចាន់ថុល មានកូនចំនួន ០៤ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន។

ជាប់ចោទពីបទ: កំហែងយក ប្រព្រឹត្តិនៅភូមិថ្នល់បែក ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡេងសាន ភេទប្រុស អាយុ ៣៨ឆ្នាំ នៅភូមិកំពង់ចិន ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិទួលទំនប់ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ប៉ោលាង (រ) ម្តាយឈ្មោះ [redacted] ឃីម (រ) ប្រពន្ធឈ្មោះ ពៅ វត្តនា មានកូន ០៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន។

ជនរងគ្រោះឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ៣៨ឆ្នាំ នៅភូមិទី១០ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិទឹកថ្លា ឃុំទំនប់ដា ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ឪពុកឈ្មោះ [redacted] អ៊ឹម (ស) ម្តាយឈ្មោះ [redacted] សុម៉ាលី (ស) ប្រពន្ធឈ្មោះ [redacted] ធីតា មានកូន ០៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន។

Scanned with CamScanner

ជនរងគ្រោះឈ្មោះ [redacted] ហេង ភេទប្រុស អាយុ ២៨ឆ្នាំ ទីទៅកន្លែងកំណើតស្ថិតនៅសង្កាត់ដេប៉ូពីរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិឡឥដ្ឋ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

ជនរងគ្រោះឈ្មោះ [redacted] ទិត្យ ភេទប្រុស អាយុ ២៩ឆ្នាំ ទីទៅកន្លែងកំណើតស្ថិតនៅភូមិក្រាំងថ្ម ឃុំមហាទាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិស្រះឈូក សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៩៤៨ ដ.ស.ព ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤២៦៩ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ ។

## អង្គហេតុកើតមានឡើងដូចតទៅ

កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ០១និង៣៥នាទី យប់ ឈ្មោះ [redacted] សុភាព បានបើកឡានដឹកឈើធ្វើផ្ទះពីស្រុកត្បែងមានជ័យ ទៅស្រុកគូលែន ពេលមកដល់ចំណុចភូមិថ្នល់បំបែក ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ មានរថយន្តចំនួន០២គ្រឿង គឺរថយន្តម៉ាកកាមរីសេរីឆ្នាំ១៩៩១ ពណ៌កណ្តុរប្រមេះ ពាក់ស្លាកលេខភ្នំពេញ2M-9141 និងរថយន្តម៉ាកកាមរីសេរីឆ្នាំ១៩៩៣ ពណ៌ស ពាក់ស្លាកលេខភ្នំពេញ 2E-6769 បើកស្ទាក់ឈ្មោះ [redacted] សុភាព ឲ្យឈប់ហើយជំរិតទារប្រាក់ចំនួន ២,០០០,០០០ រៀល (ពីរលានរៀល)។ ពេលនោះឈ្មោះ [redacted] ឡេងសាន បានទៅជួយសម្របសម្រួល តែពួកគេនៅតែទារប្រាក់ ២,០០០,០០០ រៀលដដែល ពេលនោះឈ្មោះ [redacted] ឡេងសាន ក៏បានប្តឹងកងរាជអាវុធហត្ថ ពេលកងរាជអាវុធហត្ថមកដល់ពួកគេក៏រត់គេចខ្លួនបាត់ទៅ ហើយក្នុងចំណោមពួកគេនោះ មានគ្នា៨នាក់ តែម្ចាស់ឈើស្គាល់តែឈ្មោះ [redacted] សារុម មួយប៉ុណ្ណោះ។

## កិច្ចដំណើរការ នៃការពិភាក្សាដេញដោលក្នុងពេលសវនាការ

-ចៅក្រមជំនុំជម្រះអានសញ្ញាណនៃរឿងក្តី និងចាប់ផ្តើមបន្តនីតិវិធីដូចតទៅ:

-ក្រឡាបញ្ជីអានវត្តមាន និងអវត្តមាននៅក្នុងពេលសវនាការ។

-ក្រឡាបញ្ជីអានចម្លើយ របស់ជនជាប់ចោទ និងជនរងគ្រោះ ដើមបណ្តឹង។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយបានស្តាប់អំណានចម្លើយជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះរួចមក យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ [redacted] សារុម ពិតជាបានប្រព្រឹត្តអំពើ កំហែងយក ប្រព្រឹត្តនៅភូមិ ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌដូចការចោទប្រកាន់ ដូច្នេះតំណាងអយ្យការស្នើសុំឲ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ [redacted] សារុំ តាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ក្រោយពីបញ្ចប់កិច្ចពិភាក្សាដេញដោលនាពេលសវនាការរួចមកយើងខ្ញុំសុំធ្វើសេចក្តីកត់សម្គាល់ថា កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ

Scanned with CamScanner

២០១៦ វេលាម៉ោង១ និង៣៥នាទីយប់ ឈ្មោះ [redacted] សុភាព បានបើករថយន្តដឹកឈើពីផ្ទះភូមិពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ទៅទីរួមស្រុកគូលែនទៅឲ្យឈ្មោះ [redacted] ឡេងសាន តែនៅពេលធ្វើដំណើរមកដល់ចំណុចភូមិថ្នល់បំបែក បានជួបរថយន្តពីរគ្រឿងម៉ាកកាមម៉ារីស្ទិតសេរីឆ្នាំ១៩៩១ ពណ៌កណ្ដុរប្រផេះ ពាក់ស្លាកលេខភ្នំពេញ M-9141 និងរថយន្តម៉ាកកាម៉ារីហើមស្ពាំសេរី ឆ្នាំ១៩៩៣ ពណ៌ស ពាក់ស្លាកលេខភ្នំពេញ 2E-6769 បានបើករថយន្តស្ទាក់គៀបរថយន្តខ្លួនឲ្យឈប់ដើម្បីជំរិតទារប្រាក់ ២លាន រៀល ប៉ុន្តែម្ចាស់រថយន្តពុំមានប្រាក់ឲ្យនោះទេ។ ចំណែកកូនក្ដីយើងខ្ញុំឈ្មោះ [redacted] សារុម បានច្រានចោលការចោទប្រកាន់នេះ ដោយថាខ្លួនមិនបានជំរិតទារប្រាក់ពីពួកគេឡើយ។ ពាក់ព័ន្ធ ជាមួយនឹងចេតនានៃការប្រព្រឹត្តបទល្មើសវិញ គឺកូនក្ដីរបស់យើងខ្ញុំពុំមានចេតនា ដូចគ្នានឹងបទល្មើស ដូចឈ្មោះ [redacted] ឡេងសាន និងតំណាងអយ្យការធ្វើការចោទប្រកាន់ពីបទ កំហែងយក ទេ ពីព្រោះកូនក្ដី យើងខ្ញុំធ្វើការងារជាអ្នកសារព័ត៌មាន ហើយមានកាតទទួលស្គាល់ពីក្រសួងព័ត៌មាន ធ្វើការតាមវិជ្ជាជីវៈ ក្រោយពីខ្លួនឃើញអ្នកដឹកឈើខុសច្បាប់ ហើយខ្លួនជិះរថយន្តតាមសួរនាំ និងថតរូបភាពដើម្បីយក ព័ត៌មានផ្សាយតែប៉ុណ្ណោះ មិនមែនគំរាមយកប្រាក់ដូចការចោទប្រកាន់នោះទេ។ ម្យ៉ាងទៀតកូនក្ដី យើងខ្ញុំមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសអ្វី ដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ និងសង្គម ឡើយ។ បើពិនិត្យលើផ្លូវច្បាប់វិញ រួមមានច្បាប់ស្ដីពីរបបសារព័ត៌មាន ច្បាប់រដ្ឋធម្មនុញ្ញ និងក្រមព្រហ្ម ទណ្ឌក្នុងមាត្រា៣ មាត្រា៤ មាត្រា២០ និងមាត្រា៤១ មិនបានចែងដាក់ទោសព្រហ្មទណ្ឌ លើអ្នកសារព័ត៌មានដែលចុះផ្សាយអត្ថបទ ឬបោះពុម្ពផ្សាយដែលទទួលបានព័ត៌មាន ពីប្រភពត្រឹមត្រូវ និងផ្សាយតាមវិជ្ជាជីវៈនោះទេ។ យោងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញបានចែងថា ប្រជាពលរដ្ឋខ្មែរមានសេរី ភាពខាងការ បញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយ។ ដូច្នេះក្នុងនាមយើងខ្ញុំជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំឲ្យតុលាការសម្រេចលើកលែងចោទប្រកាន់ ដើម្បីឲ្យឈ្មោះ [redacted] សារុម មានសេរីភាពដូចដើមវិញ។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹង ជនរងគ្រោះ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន និងការប្ដឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>សំអាងហេតុ</u>

១-ជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ [redacted] សារ៉ុ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ: កំហែងយក ប្រព្រឹត្តិនៅភូមិថ្នល់បែក ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] សារុម បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ខ្លួនបានជិះឡានពីក្រុងព្រះវិហារ ទៅខេត្តសៀមរាប បានជួបឡានដឹកឈើមួយគ្រឿង ប្រភេទឡានធំដឹកទំនិញ ក្រោយមកខ្លួនបានបើកឡានតាមដើម្បីសួរនាំថាឡានដឹកឈើ

របស់អ្នកណា និងបានថតដើម្បីយកព័ត៌មាន។ បន្ទាប់មកឈ្មោះ សាន បានមកដល់ ហើយឡានដឹកឈើបានទៅបាត់ឈ្មោះ សាន បានស្រែកថា អាណាហ៊ានថតឡានអញ បើហ៊ានថតឡានអញមិនឲ្យចេញរួចឡើយ បើហ៊ានបើកឡានចេញអញបុកឲ្យងាប់ ហើយបានមកវាយខ្លួនដោយប្រើដំបង និងទាញកាមេរ៉ា ប្រដាប់ថត ប័ណ្ណសម្គាល់រថយន្ត ប័ណ្ណសម្គាល់ម៉ូតូ និងប័ណ្ណបើកបរពីក្នុងដៃរបស់ខ្លួន ខ្លួនក៏បានរត់គេចចូលព្រៃ ចំណែកគ្នីគ្នា០៣នាក់ទៀត បានរត់បែកផ្លូវគ្នាអស់ ហើយខ្លួនមិនបានជំរិតទារប្រាក់គេឡើយ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡេងសាន បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: កាលថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ ខ្លួនបានបើកឡានពីស្រុកគូលែន ទៅខេត្តសៀមរាប លុះដល់ចំណុចភូមិថ្មី ស្រុកគូលែន ខេត្តព្រះវិហារ ស្រាប់តែឈ្មោះ[redacted]សារុម និងបក្សពួក ៤នាក់ ទៀត មកកាត់ឡានឲ្យឈប់ ហើយមកទារប្រាក់ចំនួន ២,០០០,០០០៛ (ពីរលានរៀល) ដោយសំអាងថាជាអ្នកកាសែតមកពីក្រសួង។ ខ្លួនបានសម្រួលសុំឲ្យតែ១០ម៉ឺនរៀល ឬ២០ម៉ឺនរៀល តែពួកគាត់មិនព្រម ហើយខ្លួនក៏ប្តឹងទៅកងរាជអាវុធហត្ថខេត្តព្រះវិហារ បន្ទាប់មកឈ្មោះ [redacted] សារុម និងបក្សពួកក៏បានរត់គេចខ្លួនបាត់ទៅ។

៤-ជនរងគ្រោះឈ្មោះ [redacted] សុភាព ឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] ទិត្យ បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ប្រហាក់ប្រហែលគ្នាថា: កាលពីឆ្នាំ២០១៦ ខ្លួនបានស៊ីឈ្នួលដឹកឈើឲ្យឈ្មោះ [redacted] ឡេងសាន បានដឹកឈើប្រភេទផ្ចឹកចំនួន ២គីបជាង ដោយមានគ្នា០៤នាក់ ដោយដឹកពីទីរួមខេត្តព្រះវិហារទៅ ស្រុកគូលែន ស្រាប់តែមានឡានមួយគ្រឿង ជិះគ្នាប្រាំនាក់តាមឡានរបស់ខ្លួន មកដល់ចំណុចភូមិថ្មី ឃុំថ្មី ឡានខ្លួនក៏ឈប់ ហើយមនុស្សទាំងប្រាំនាក់នោះក៏ចុះមកសួរនាំ និងប្រាប់ថាមកពីខាងក្រសួង និងទាមទារឲ្យដោះស្រាយប្រាក់ចំនួន២,០០០,០០០៛ (ពីរលានរៀល) ខ្លួនគ្មានលុយក៏បានទូរស័ព្ទទៅថៅកែមកដោះស្រាយ ហើយខ្លួនក៏បានបើកឡានចេញទៅ។

***-យោងតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃ ក្រមព្រហ្មទណ្ឌបានចែងថា:***

***-មាត្រា ៣៦៣ និយមន័យនៃការកំហែងយក***

អំពើកំហែងយក គឺជាអំពើប្រព្រឹត្តដោយការប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬដោយការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ:

១-ហត្ថលេខា ឬស្នាមម្រាមដៃ ។

២-ការសន្យា ឬ ការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថ៌កំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ។

***-មាត្រា ៣៦៤ ទោសដែលត្រូវអនុវត្ត***

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០ (បួនលាន) រៀល ទៅ ១០,០០០,០០០ (ដប់លាន) រៀល ។

៥-យោងលើចម្លើយរបស់ជនត្រូវចោទ គឺគ្រាន់តែជាការបដិសេធគេចវេះមិនទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត គប្បីតុលាការមិនយកមកពិចារណា។

៦-យោងលើចម្លើយរបស់ដើមបណ្តឹង សាក្សី និងភស្តុតាងទាំងអស់ដែលមានក្នុងសំណុំរឿងបញ្ជាក់ថា ជនជាប់ចោទខាងលើនេះពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន គប្បីតុលាការយកមកពិចារណា។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ [redacted] សារុំ ដែលបានគំរាមកំហែងយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយសំអាងខ្លួនជាអ្នកសារព័ត៌មាន ឆ្លើយតបទៅនឹងលក្ខខណ្ឌនិយមន័យ នៃបទល្មើស កំហែងយក ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ [redacted] សារុំ ជាសកម្មភាពនាំឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និង ធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងដែលសង្គមត្រូវការពារ។ មិនតែប៉ុណ្ណោះសកម្មភាពរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់វិធានការរបស់រដ្ឋ ដែលមានគោលបំណងទប់ស្កាត់ បង្ក្រាបការបង្កអសន្តិសុខសុវត្ថិភាពសាធារណៈផងដែរ។

៩-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ [redacted] សារុំ ជាសមត្ថជន (នីតិជន) មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ការប្រព្រឹត្តរបស់ជនជាប់ចោទអាចពិចារណា យល់ដឹងបាននូវចំណងទាក់ទងហេតុ និងផល អំពើ និងបច្ច័យដែលកើតឡើង តែជនជាប់ចោទនៅតែប្រព្រឹត្តដោយចេតនា។ ពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា ជនជាប់ចោទមានវិបល្លាសស្មារតីក្នុងការប្រព្រឹត្តបទល្មើសនោះទេ។

១០-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយបានស្តាប់អំណានចម្លើយជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះរួចមក យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារុម ហៅឈុន សារុំ ពិតជាបានប្រព្រឹត្តអំពើ កំហែងយក ប្រព្រឹត្តនៅភូមិថ្នល់បំបែក ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌដូចការចោទប្រកាន់ ដូច្នេះតំណាង អយ្យការស្នើសុំឲ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ [redacted] សារុំ តាមច្បាប់។

១១-យល់ឃើញថា ឆ្លងតាមកិច្ចពិភាក្សាដេញដោល និងការពិនិត្យភស្តុតាង ព្រមទាំងស្តាប់ចម្លើយនានារបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ មានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទបានប្រព្រឹត្តអំពើកំហែងយក គប្បីតុលាការពិចារណាប្រកាស ពិរុទ្ធភាពលើជនជាប់ចោទ។

## ហេតុដូច្នេះ

## ទនិច្ឆ័យសេចក្តី

**១-ប្រកាសពិរុទ្ធភាពៈ**

ឈ្មោះ [redacted] សារុម ហៅ [redacted] សារុំ ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើចំការ និងជាប្រធានសាខាសារពត៌មានតាព្រហ្មប្រចាំខេត្តពោធិ៍សាត់ ទីកន្លែងកំណើតស្ថិតនៅឃុំស្តេចគង់ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិថ្កុកដង្កោ ឃុំថ្កុកដង្កោ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] ទឹម (ស) ម្តាយឈ្មោះ យ៉ន់ (ស) ប្រពន្ធឈ្មោះ [redacted] ចាន់ថុល មានកូន

ចំនួន ០៤នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន។

ជាប់ចោទពីបទ: កំហែងយក ប្រព្រឹត្តិនៅភូមិថ្នល់បែក ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

**២-ផ្តន្ទាទោសជនជាប់ចោទ ៖**

ឈ្មោះ [redacted]ហុកលីម ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិដូចខាងលើ)។

ពិន័យជាប្រាក់ ៤,០០០,០០០ (បួនលាន) រៀល ។

ពីបទ កំហែងយក ប្រព្រឹត្តិនៅភូមិថ្នល់បែក ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

**៣-សាលក្រមនេះជំនុំជម្រះ**

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ដោយកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡេងសាន ជនរងគ្រោះឈ្មោះ [redacted] ទិត្យ, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] សុភាព និងជនជាប់ចោទឈ្មោះ [redacted] សារុម ហៅ[redacted] សារុម ។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា:** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និង ត្រា:** [redacted]

---

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១៣កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ខេត្តព្រះវិហារ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១
**ក្រឡាបញ្ជីសវនាការ**

[redacted]

Scanned with CamScanner